ក

# មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៦-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៤៥ ស្តីពី លក្ខន្តិកៈដោយឡែកនៃយោធិនបម្រុង ៦៧៣៨

០៩-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៤៧ ស្តីពី ការប្តូរប្រភេទក្របខ័ណ្ឌជូនមន្ត្រីរាជការ ចំនួន ០៤ រូប ទៅក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និង ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ៦៧៤៨

០៩-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៤៨ ស្តីពី ការប្រោសព្រះរាជទាន ចំពោះលោកវរសេនីយ៍ត្រី ស្រួន ឡាំ នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេនា ៦៧៥០

០៩-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៤៩ ស្តីពី ការប្រោសព្រះរាជទាន ចំពោះ ថ្នាក់ដឹកនាំយោធភូមិភាគទី ៩ នៃកងទ័ពប្រជាជនវៀតណាម និង ថ្នាក់ដឹកនាំក្រុង កិនធឺ ចំនួន ០២ រូប បានជួយកសាងសមិទ្ធផល ជូនប្រជាជន និង បានកសាងស្តូបបូជនីយកិច្ច មិត្តភាព កម្ពុជា-វៀតណាម នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៦៧៥១

០៩-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៥០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះ នាយនគរបាលជាតិ ចំនួន ១១ រូប នៃក្រសួងមហាផ្ទៃ ដែលបានខិតខំបំរើជាតិ សាសនា ព្រះមហាក្សត្រ ៦៧៥២

០៩-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៥១ ស្តីពី ការប្រោសព្រះរាជទានតែងតាំងលោកជំទាវ ញឹម សុខាល័យ ជា ឧកញ៉ា ៦៧៥៣

០៩-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៥២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ នាយនគរបាលជាតិ និងសប្បុរសជន ចំនួន ៥៧ រូប បានបរិច្ចាគធនធាន ចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធសង្គមជាតិ និង សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ នៅស្រុកបាណន់ ខេត្តបាត់ដំបង ៦៧៥៤

០៩-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៥៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ នាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ១៦២ រូប បានខិតខំប្រឹងប្រែងបំពេញភារកិច្ច ថែរក្សាការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និង ស្ថេរភាពសង្គម ដើម្បីផលប្រយោជន៏របស់ប្រទេសជាតិ និងប្រជាពលរដ្ឋបានល្អប្រសើរនៅស្រុកបាណន់ ខេត្តបាត់ដំបង ៦៧៥៦

០៩-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៥៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ នាយទាហាន ចំនួន ២២ រូប នៃវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល មានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ៦៧៦២

១១-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៥៥ ស្តីពី ការផ្លាស់ឯកឧត្តម **ខ៉េត ស៊ីសូដា** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព ប្រតិភូអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការយូណេស្កូ ឱ្យវិលត្រឡប់មកបំពេញបេសកកម្មក្នុងប្រទេសវិញ និង ត្រូវបានតែងតាំងឯកឧត្តម **នុត ណារ៉ាង** ជំនួសវិញ ៦៧៦៣

## II-រាជរដ្ឋាភិបាល

## អនុក្រឹត្យ

០៦-៨-២០១០ -អនុក្រឹត្យលេខ ៩៣អនក្រ.បក ស្តីពី ការផ្ទេរធនធានពីថវិការជាតិជូនមូលនិធិឃុំ សង្កាត់ ៦៧៦៤

០៦-៨-២០១០ -អនុក្រឹត្យលេខ ៩៤ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦៧៦៨

***-អនុក្រឹត្យលេខ ៩៥ អនក្រ.បក មិនទាន់បានទទួល***

១២-៨-២០១០ -អនុក្រឹត្យលេខ ៩៦ អនក្រ.បក ស្តីពី ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៦៧៧០

១២-៨-២០១០ -អនុក្រឹត្យលេខ ៩៧ អនក្រ.បក ស្តីពី ការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១២៨ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារ ធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៦៧៧២

១៦-៨-២០១០ -អនុក្រឹត្យលេខ ៩៨ អនក្រ.បក ស្តីពី ការទទួលស្គាល់ សាកលវិទ្យាល័យកម្ពុជាអន្តរជាតិ ៦៧៧៤

០២-៨-២០១០ -អនុក្រឹត្យលេខ ៨២១ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៦៧៧៧

០២-៨-២០១០ -អនុក្រឹត្យលេខ ៨២២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៧៧៨

០២-៨-២០១០ -អនុក្រឹត្យលេខ ៨២៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៧៧៩

០២-៨-២០១០ -អនុក្រឹត្យលេខ ៨២៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៧៨០

០២-៨-២០១០ -អនុក្រឹត្យលេខ ៨២៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៧៨៣

០៣-៨-២០១០ -អនុក្រឹត្យលេខ ៨២៦ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៦៧៨៧

០៣-៨-២០១០ -អនុក្រឹត្យលេខ ៨២៧ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៦៧៨៨

០៤-៨-២០១០ -អនុក្រឹត្យលេខ ៨២៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៧៩០

០៤-៨-២០១០ -អនុក្រឹត្យលេខ ៨២៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៧៩១
០៤-៨-២០១០ -អនុក្រឹត្យលេខ ៨៣០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៧៩២
០៤-៨-២០១០ -អនុក្រឹត្យលេខ ៨៣១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៦៧៩៤
០៤-៨-២០១០ -អនុក្រឹត្យលេខ ៨៣២ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៦៧៩៥
០៤-៨-២០១០ -អនុក្រឹត្យលេខ ៨៣៣ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៦៧៩៦
០៤-៨-២០១០ -អនុក្រឹត្យលេខ ៨៣៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៧៩៧
០៤-៨-២០១០ -អនុក្រឹត្យលេខ ៨៣៥ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៦៧៩៨
០៥-៨-២០១០ -អនុក្រឹត្យលេខ ៨៣៦ អនក្រ.តត ស្តីពី ការដាក់ចូលនិវត្តន៍ និង តែងតាំងមន្ត្រីរាជការ ៦៧៩៩
០៥-៨-២០១០ -អនុក្រឹត្យលេខ ៨៣៧ អនក្រ.តត ស្តីពី ការទទួលស្គាល់ប្រធានកិត្តិយស គណៈកម្មាធិការកណ្តាល អាណត្តិទី ៥ សមាជិកបំរុង ឥស្សរជន និង អគ្គលេខាធិការ អគ្គលេខាធិការរង កាកបាទក្រហមកម្ពុជា ៦៨០០
០៥-៨-២០១០ -អនុក្រឹត្យលេខ ៨៣៨ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ៦៨០៣
០៥-៨-២០១០ -អនុក្រឹត្យលេខ ៨៣៩ អនក្រ.តត ស្តីពី ការប្រគល់ឋានន្តរសក្តិ នាយទាហាន ៦៨០៤
០៦-៨-២០១០ -អនុក្រឹត្យលេខ ៨៤០ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៦៨០៥
០៦-៨-២០១០ -អនុក្រឹត្យលេខ ៨៤១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៦៨០៦
០៦-៨-២០១០ -អនុក្រឹត្យលេខ ៨៤២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៨០៧
០៦-៨-២០១០ -អនុក្រឹត្យលេខ ៨៤៣ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៦៨០៨
០៦-៨-២០១០ -អនុក្រឹត្យលេខ ៨៤៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៨០៩
០៦-៨-២០១០ -អនុក្រឹត្យលេខ ៨៤៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦៨១១
០៩-៨-២០១០ -អនុក្រឹត្យលេខ ៨៤៦ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាព ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម ៦៨១២
០៩-៨-២០១០ -អនុក្រឹត្យលេខ ៨៤៧ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាព អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ៦៨១៤

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៥-៨-២០១០ -ប្រកាសលេខ ៦៥៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេច ២ ហ្គាមេន បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦៨១៦

០៥-៨-២០១០ -ប្រកាសលេខ ៦៥៨ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមមីចិច (ខេមបូឌា) អិមអេហ្វជី បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦៨២០

០៥-៨-២០១០ -ប្រកាសលេខ ៦៥៩ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ថៃរ៉ុង (ខេមបូឌា) នីតធីង បង្កើតរោងចក្រ ផលិតស្រោមជើង ៦៨២៤

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៨-១១-២០០៩-លិខិតបញ្ជាក់លេខ ៤៥២៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទិមាន សាគរ** ៦៨២៨

១៨-១១-២០០៩-លិខិតបញ្ជាក់លេខ ៤៥២៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទន្លេសាប បាយអូម៉ាស ផៅវ័រ ផ្លាន** ៦៨៣០

១៨-១១-២០០៩-លិខិតបញ្ជាក់លេខ ៤៥២៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វី ខណ្ណនី ហ្វូណាន់សាន អ៊ិនវេសមេន គ្រុប** ៦៨៣២

១៨-១១-២០០៩-លិខិតបញ្ជាក់លេខ ៤៥៣០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីសនី ហ្វាម៉ា អ៊ីមផត អិចផត** ៦៨៣៤

១៨-១១-២០០៩-លិខិតបញ្ជាក់លេខ ៤៥៣២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មីគស ហ្វាម៉ា សេនធ័រ** ៦៨៣៦

១៨-១១-២០០៩-លិខិតបញ្ជាក់លេខ ៤៥៣៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខ្មែរ ហ្គិណាស ប្រ៊ីវ៉ាយឌើរ** ៦៨៣៨

១៨-១១-២០០៩-លិខិតបញ្ជាក់លេខ ៤៥៤០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាល់ធី ស៊ីធីស ត្រេនស្ព័រ ថេសិន & អ៊ិនវេសមេន** ៦៨៤០

១៨-១១-២០០៩-លិខិតបញ្ជាក់លេខ ៤៥៤២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ញូវ ប៊ី លីមីធីត** ៦៨៤២

១៨-១១-២០០៩-លិខិតបញ្ជាក់លេខ ៤៥៤៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាប់ប៊ែលយូ ដាប់ប៊ែលយូ អិន អេស ខប** ៦៨៤៣

១៩-១១-២០០៩-លិខិតបញ្ជាក់លេខ ៤៥៦១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ាន ប្អូ ស្តាយ យ៉ូញូ ស្កុត ខមភេនី** ៦៨៤៥

១៩-១១-២០០៩-លិខិតបញ្ជាក់លេខ ៤៥៦២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេមីស្វ អ៊ិនធើណេសិនណល តិធីអ៊ី អិលធីឌី** ៦៨៤៧

១៩-១១-២០០៩-លិខិតបញ្ជាក់លេខ ៤៥៦៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្រេន ថារី អ៊ឹមផត អិចផត** ៦៨៤៩

២០-១១-២០០៩-លិខិតបញ្ជាក់លេខ ៤៥៦៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន **ម៉ូបឹឡីធីខ័ន អេសឌី អិន ប៊ីអេចឌី (ខេមបូឌា)** ៦៨៥១

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៤៥

## ស្តីពី

## លក្ខន្តិកៈដោយឡែកនៃយោធិនបម្រុង

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ០៧/នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានទ្រង់យល់ព្រះរាជក្រមលេខជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/១២០៦/០៣០ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកាតព្វកិច្ចយោធា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១០

## ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ព្រះរាជក្រឹត្យនេះ មានគោលដៅបង្កើតក្របខណ្ឌយោធិនបម្រុង នៃកងយោធពលខេមរភូមិន្ទ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

ព្រះរាជក្រឹត្យនេះមានគោលបំណងរៀបចំ ៖

-កម្លាំងបំពេញសេវាសកម្ម ក្នុងអង្គភាពយោធិនអាជីព ពេលមានតម្រូវការចាំបាច់របស់ប្រទេសជាតិ

-កម្លាំងត្រៀមរង់ចាំបំពេញភារកិច្ច តាមតម្រូវការនៃកងយោធពលខេមរភូមិន្ទ។

**មាត្រា៣.-**

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះ ៖

១-យោធិនអាជីពដែលចូលនិវត្តន៍ ឬលាឈប់ពីការងារមុនអាយុកំណត់ចូលនិវត្តន៍។

២-យោធិនជាប់កិច្ចសន្យាដែលបានបញ្ចប់កិច្ចសន្យា។

៣-ពលរដ្ឋដែលបានបញ្ចប់កាតព្វកិច្ចយោធា។

៤-អ្នកឯកទេសជំនាញ ដែលបានបញ្ចប់កិច្ចសហប្រតិបត្តិការបំពេញបេសកកម្មស្រាវជ្រាវ ឬអនុវត្តផ្ទាល់នូវកិច្ចការដែលជាប្រយោជន៍សាធារណៈនៃកងយោធពលខេមរភូមិន្ទ ដែលមានរយៈពេលស្មើនឹងកាតព្វកិច្ចយោធា ចំនួន១៨(ដប់ប្រាំបី)ខែ។

**មាត្រា៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងព្រះរាជក្រឹត្យនេះ មាននិយមន័យ ដូចតទៅ ៖

**-ស្ថានភាពសេវាសកម្ម** សំដៅដល់ស្ថានភាពដែលយោធិនបម្រុង ត្រូវបានអញ្ជើញមកបំពេញការងារ ក្នុងមុខនាទីណាមួយ ក្នុងក្របខណ្ឌយោធិនអាជីព ក្នុងរូបភាពជាបុគ្គល ឬជាក្រុម។

**-ស្ថានភាពបម្រុងប្រតិបត្តិការ** សំដៅដល់ស្ថានភាពដែលយោធិនបម្រុង រង់ចាំទទួលការបញ្ជាតែងតាំង ឬអញ្ជើញឲ្យចូលមកបំពេញការងារ ឬសកម្មភាពយោធាណាមួយក្នុងសេវាសកម្ម ឬបំពេញការសកម្មតាមតម្រូវការចាំបាច់ របស់ក្រសួងការពារជាតិ។

**-ការិយកម្ម** សំដៅដល់កិច្ចការ ឬការងារដែលគេត្រូវធ្វើ។

**-គារវកិច្ច** សំដៅដល់កាយវិការគំនាប់ ការគោរពគ្នាទៅវិញទៅមក តាមបែបជាយោធា។

**-គោលរបប** សំដៅដល់កញ្ចប់របបដែលផ្តល់ឲ្យ ដើម្បីបំពេញការងាររួមមានផ្នែកហិរញ្ញវត្ថុ ផ្នែកភស្តុភារ និងយោធបរិក្ខារ។

## ជំពូកទី២
## ស្ថាប័នគ្រប់គ្រង

**មាត្រា៥.-**

ក្រសួងការពារជាតិ ជាស្ថាប័នទទួលខុសត្រូវ ក្នុងការគ្រប់គ្រងយោធិនបម្រុងទាំងអស់ រាប់ទាំងក្របខណ្ឌ ការតែងតាំងផ្លាស់ប្តូរ ដោយមាននាយកដ្ឋានបុគ្គលិក ជាសេនាធិការ។

**មាត្រា៦.-**

ក្របខណ្ឌយោធិនបម្រុង ត្រូវបានបែងចែកជាប្រភេទ ឋានានុក្រមឋានន្តរសក្តិដូចយោធិនអាជីពដែរ។

## ជំពូកទី៣
## លក្ខណសម្បត្តិយោធិនបម្រុង

**មាត្រា៧.-**

លក្ខណសម្បត្តិនៃការចូលជាយោធិនបម្រុង៖

-មានសុខភាពល្អ និងកាយសម្បទាតាមតម្រូវការ ដើម្បីបំពេញការងារ

-មិនធ្លាប់ត្រូវបានតុលាការផ្តន្ទាទោស។

**មាត្រា៨.-**

ការសម្រេចឲ្យចូលបម្រើក្នុងក្របខណ្ឌយោធិនបម្រុង នៃកងយោធពលខេមរភូមិន្ទចំពោះ ៖

-នាយទាហានថ្នាក់ឧត្តមសេនីយ៍ ឧត្តមនាវី កំណត់ដោយព្រះរាជក្រឹត្យ

-នាយទាហានថ្នាក់វរសេនីយ៍ឯក វរនាវីឯក កំណត់ដោយអនុក្រឹត្យ

-នាយទាហានថ្នាក់វរសេនីយ៍ទោ វរនាវីទោចុះកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ។

យោធិនបម្រុង មានអត្តលេខថ្មីដោយមានភ្ជាប់អក្សរ " ប " នៅខាងដើម។

យោធិនបម្រុង មានឯកសណ្ឋានដូចគ្នានឹងយោធិនអាជីពដែរ។

**មាត្រា៩.-**

យោធិនបម្រុងត្រូវបានកំណត់អាយុតាមឋានន្តរសក្តិ ដូចខាងក្រោម៖

-នាយទាហានបម្រុង នាយទាហានរងបម្រុង ត្រូវបានកំណត់អាយុ ដូចតាមលក្ខខណ្ឌកំណត់អាយុចូលនិវត្តន៍ តាមឋានន្តរសក្តិនៃយោធិនអាជីព ដោយបូកបន្ថែមរយៈពេល៥(ប្រាំ)ឆ្នាំ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

-ពលទាហានបម្រុង អាយុកំណត់រហូតត្រឹម ៤៥(សែសិបប្រាំ)ឆ្នាំ។

ការកំណត់អាយុយោធិនបម្រុង អាចកែប្រែតាមតម្រូវការចាំបាច់របស់ប្រទេសជាតិ។

នាយទាហានថ្នាក់ឧត្តមសេនីយ៍ត្រូវដាក់ក្នុងក្របខណ្ឌយោធិនបម្រុងអស់មួយជីវិត។

## ជំពូកទី៤
## ស្ថានភាព ភារកិច្ច និងការទទួលខុសត្រូវរបស់យោធិនបម្រុង

**មាត្រា១០.-**

យោធិនបម្រុងគ្រប់រូបស្ថិតនៅក្នុងស្ថានភាពណាមួយ ដូចខាងក្រោម៖

-សេវាសកម្ម

-បម្រុងប្រតិបត្តិការ។

### ផ្នែកទី១
### សេវាសកម្ម

**មាត្រា១១.-**

ក្នុងស្ថានភាពសេវាសកម្ម យោធិនបម្រុងត្រូវបានអញ្ជើញមក ដើម្បីបំពេញការងារក្នុងមុខនាទីណាមួយ ក្នុងក្របខណ្ឌយោធិនអាជីពក្នុងរូបភាពជាបុគ្គល ឬជាក្រុមមានរយៈពេលពី១(មួយ)ខែ ដល់ ៣(បី)ខែ ឬក្នុងករណីចាំបាច់អាចបន្តដល់៦(ប្រាំមួយ)ខែ។

**មាត្រា១២.-**

ក្នុងសេវាសកម្មយោធិនបម្រុងដែលកំពុងបំពេញការិយកម្ម ហ្វឹកហ្វឺនបំប៉ន និងបំពេញការងារ មានសិទ្ធិ កាតព្វកិច្ច និងភារកិច្ចដូចគ្នានឹងយោធិនអាជីព ដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ។

**មាត្រា១៣.-**

យោធិនបម្រុង មានសិទ្ធិស្លៀកពាក់ឯកសណ្ឋានបាន នៅក្នុងរយៈពេលអញ្ជើញមកបំពេញការិយកម្ម ហ្វឹកហ្វឺនបំប៉ន បំពេញការងារក្នុងសេវាសកម្ម និងនៅក្នុងឱកាសចូលរួម ធ្វើសន្និបាត បុណ្យ ឬពិធីផ្សេងៗដែលមានលក្ខណៈជាយោធា។

**មាត្រា១៤.-**

យោធិនបម្រុងដែលបំពេញសកម្មភាពក្នុងសេវាសកម្ម មានសិទ្ធិទទួលបានគោលរបប និងការឧបត្ថម្ភផ្សេងៗដូចគ្នានឹងយោធិនអាជីព។

មន្ត្រីរាជការស៊ីវិលដែលត្រូវបានអញ្ជើញមកបម្រើក្នុងសេវាសកម្ម មានសិទ្ធិបើកបៀវត្សមូលដ្ឋានទីញ្ញាណ និងបន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិលនៅអង្គភាពដើមរបស់ខ្លួន។ ការឧបត្ថម្ភផ្សេងៗ និងរបបផ្គត់ផ្គង់ប្រចាំថ្ងៃគឺជាបន្ទុករបស់ក្រសួងការពារជាតិ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា១៥.-**

យោធិនបម្រុងដែលជាអ្នកកាន់កាប់គ្រប់គ្រងមូលនិធិ សម្ភារបរិក្ខារ ឬស្បៀងហើយធ្វើឲ្យខូចខាតបាត់បង់ ឬយោធិនបម្រុងណាបានបង្កឲ្យមានការបំផ្លិចបំផ្លាញ បាត់បង់ ឬខូចខាតនូវយោធបរិក្ខារ សម្ភារៈគ្រឿងបំពាក់ដែលបានប្រគល់ឲ្យ ត្រូវទទួលខុសត្រូវលើសំណង។ ក្នុងករណីធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសតាមច្បាប់។

**មាត្រា១៦.-**

យោធិនបម្រុងមានកាតព្វកិច្ចរក្សាការសម្ងាត់ អំពីហេតុការណ៍និងព័ត៌មាន ដែលខ្លួនបានដឹងក្នុងពេលបំពេញភារកិច្ច និងបទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ ដែលពាក់ព័ន្ធនឹងការរំលោភលើកាតព្វកិច្ចរក្សាការសម្ងាត់យោធា ឬការសម្ងាត់ខាងវិជ្ជាជីវៈ។

ការពង្វាង ឬការផ្តល់ព័ត៌មាន នូវលិខិតស្នាម ឬឯកសារនៃសេវាផ្ទុយពីបទបញ្ជាទៅឲ្យតតិយជន ត្រូវហាមឃាត់។

**មាត្រា១៧.-**

យោធិនបម្រុងក្នុងសេវាសកម្ម មានករណីយកិច្ចត្រូវធ្វើគារវកិច្ចទៅតាមលំដាប់ឋានន្តរសក្តិ។ បើឋានន្តរសក្តិ នឹងអតីតភាពការងារស្មើគ្នា យោធិនអាជីពមានសិទ្ធិបញ្ជាលើយោធិនបម្រុង។

**មាត្រា១៨.-**

យោធិនបម្រុងស្ថិតក្នុងសេវាសកម្ម ត្រូវទទួលទណ្ឌកម្មនិងវិន័យដូចយោធិនអាជីព។

## ផ្នែកទី២
## បម្រុងប្រតិបត្តិការ

**មាត្រា១៩.-**

ក្នុងស្ថានភាពបម្រុងប្រតិបត្តិការ យោធិនបម្រុងត្រូវអញ្ជើញមកបំពេញការិយកម្ម តាមតម្រូវការចាំបាច់របស់ក្រសួងការពារជាតិ។

ស្ថានភាពបម្រុងប្រតិបត្តិការមានរយៈពេល៥(ប្រាំ)ឆ្នាំ និងអាចបន្តទៀតបានតាមតម្រូវការចាំបាច់របស់ក្រសួងការពារជាតិ។

**មាត្រា២០.-**

ក្នុងរយៈពេលបំពេញការិយកម្មនិងការហ្វឹកហ្វឺនបំប៉ន យោធិនបម្រុងត្រូវបានទទួលនូវឯកសណ្ឋាន យោធបរិក្ខារចាំបាច់ ការឧបត្ថម្ភផ្សេងៗ និងរបបហូបប្រចាំថ្ងៃ។ ចំពោះឯកសណ្ឋាន និងយោធបរិក្ខារបណ្ដាក់ទាំងនោះ ត្រូវប្រគល់សងមកវិញនៅពេលបញ្ចប់។



## ជំពូកទី៥
## ការតែងតាំង

**មាត្រា២១.-**

នាយទាហានបម្រុង នាយទាហានរងបម្រុងត្រូវជ្រើសចេញពី៖

-នាយទាហាន នាយទាហានរងអាជីព ដែលចូលនិវត្តន៍

-នាយទាហាន នាយទាហានរងអាជីពដែលបានលាឈប់ពីកងទ័ព

-យោធិនជាប់កិច្ចសន្យាដែលបញ្ចប់កិច្ចសន្យា

-មន្ត្រីរាជការស៊ីវិល អ្នកឯកទេសជំនាញ ជនស៊ីវិលបានបញ្ចប់កាតព្វកិច្ចយោធាដែលរដ្ឋមន្ត្រីក្រសួងការពារជាតិយល់ថាមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើការបណ្តុះបណ្តាលហ្វឹកហ្វឺនតែងតាំងជានាយទាហានបម្រុង នាយទាហានរងបម្រុង។

**មាត្រា២២.-**

យោធិនបម្រុង ដែលត្រូវបានតែងតាំងជានាយទាហានបម្រុង នាយទាហានរងបម្រុង ត្រូវតែទទួលបានការហ្វឹកហ្វឺនបំប៉នរយៈពេលពី៣(បី)ខែ ទៅ៦(ប្រាំមួយ)ខែ នៅតាមសាលាយោធាណាមួយ ។

ចំពោះយោធិនបម្រុង ដែលមានអតីតភាពពីយោធិនអាជីព ពុំតម្រូវឲ្យមានការហ្វឹកហ្វឺនបំប៉នទៀតទេ។

## ជំពូកទី៦
## ការដំឡើងឋានន្តរសក្តិ

**មាត្រា២៣.-**

យោធិនបម្រុង ដែលមានអតីតភាពជាយោធិនអាជីព ត្រូវមានឋានន្តរសក្តិយ៉ាងតិចស្មើនឹងឋានន្តរសក្តិ ដែលខ្លួនមានកាលនៅក្នុងក្របខណ្ឌយោធិនអាជីព។

**មាត្រា២៤.-**

ការដំឡើងឋានន្តរសក្តិនាយទាហានរងបម្រុង ប្រព្រឹត្តទៅតាមអតីតភាពឋានន្តរសក្តិ និងសកម្មភាពបំពេញការិយកម្មក្នុងកងយោធពលខេមរភូមិន្ទ៖

-ពលបាលត្រីបម្រុង ចក្របាលត្រីបម្រុង អាចដំឡើងឋានន្តរសក្តិជាពលបាលទោបម្រុង ចក្របាលទោបម្រុង លុះត្រាតែសាមីយោធិនបម្រុងនោះ មានអតីតភាពឋានន្តរសក្តិ ២(ពីរ)ឆ្នាំ និងបំពេញការិយកម្ម២(ពីរ)លើក

-ពលបាលទោបម្រុង ចក្របាលទោបម្រុង អាចដំឡើងឋានន្តរសក្តិជាពលបាលឯកបម្រុង ចក្របាលឯកបម្រុង លុះត្រាតែសាមីយោធិនបម្រុងនោះ មានអតីតភាពឋានន្តរសក្តិ ២(ពីរ)ឆ្នាំ និងបំពេញការិយកម្ម២(ពីរ)លើក



-ពលបាលឯកបម្រុង ចក្របាលឯកបម្រុង អាចដំឡើងឋានន្តរសក្តិជាព្រិន្ទបាលទោបម្រុង នាយចក្របាលទោបម្រុង លុះត្រាតែសាមីយោធិនបម្រុងនោះ មានអតីតភាពឋានន្តរសក្តិ ២(ពីរ)ឆ្នាំ និងបំពេញការិយកម្ម២(ពីរ)លើក

-ព្រិន្ទបាលទោបម្រុង នាយចក្របាលទោបម្រុង អាចដំឡើងឋានន្តរសក្តិជាព្រិន្ទបាលឯកបម្រុង នាយចក្របាលឯកបម្រុង លុះត្រាតែសាមីយោធិនបម្រុងនោះ មានអតីតភាពឋានន្តរសក្តិ៣(បី)ឆ្នាំ និងបំពេញការិយកម្ម៣(បី)លើក

-ព្រិន្ទបាលឯកបម្រុង នាយចក្របាលឯកបម្រុង អាចដំឡើងឋានន្តរសក្តិជានាយចំណង់បម្រុង នាយនាវីចំណង់បម្រុង លុះត្រាតែសាមីយោធិនបម្រុងនោះ មានអតីតភាពឋានន្តរសក្តិ៣(បី) ឆ្នាំ បំពេញការិយកម្ម៣(បី)លើក និងហ្វឹកហ្វឺនបំប៉នដើម្បីតែងតាំងជានាយទាហានបម្រុង នាយនាវីបម្រុង។

**មាត្រា២៥.-**

ការដំឡើងឋានន្តរសក្តិនាយទាហានបម្រុង ប្រព្រឹត្តទៅតាមអតីតភាពឋានន្តរសក្តិ និងសកម្មភាពបំពេញការិយកម្ម ក្នុងកងយោធពលខេមរភូមិន្ទ៖

ក-ការដំឡើងឋានន្តរសក្តិថ្នាក់អនុសេនីយ៍៖

-នាយចំណង់បម្រុង នាយនាវីចំណង់បម្រុងអាចដំឡើងឋានន្តរសក្តិជាអនុសេនីយ៍ត្រីបម្រុង អនុនាវីត្រីបម្រុង លុះត្រាតែសាមីយោធិនបម្រុងនោះមានអតីតភាពឋានន្តរសក្តិ ២(ពីរ)ឆ្នាំ និងបានបំពេញការិយកម្ម២(ពីរ)លើក

-អនុសេនីយ៍ត្រីបម្រុង អនុនាវីត្រីបម្រុងអាចដំឡើងឋានន្តរសក្តិជាអនុសេនីយ៍ទោបម្រុង អនុនាវីទោបម្រុង លុះត្រាតែសាមីយោធិនបម្រុងនោះ មានអតីតភាពឋានន្តរសក្តិ ៣(បី) ឆ្នាំ និងបានបំពេញការិយកម្ម២(ពីរ)លើក

-អនុសេនីយ៍ទោបម្រុង អនុនាវីទោបម្រុង អាចដំឡើងឋានន្តរសក្តិជាអនុសេនីយ៍ឯកបម្រុង អនុនាវីឯកបម្រុង លុះត្រាតែសាមីយោធិនបម្រុងនោះ មានអតីតភាពឋានន្តរសក្តិ ៣(បី) ឆ្នាំនិងបានបំពេញការិយកម្ម២(ពីរ)លើក

-អនុសេនីយ៍ឯកបម្រុង អនុនាវីឯកបម្រុង អាចដំឡើងឋានន្តរសក្តិជាវរសេនីយ៍ត្រីបម្រុង វរនាវីត្រីបម្រុង លុះត្រាតែសាមីយោធិនបម្រុងនោះ មានអតីតភាពឋានន្តរសក្តិ ៤(បួន) ឆ្នាំ បានបំពេញការិយកម្ម២(ពីរ)លើក និងហ្វឹកហ្វឺនបំប៉ន ដើម្បីតែងតាំងថ្នាក់វរសេនីយ៍បម្រុង វរនាវីបម្រុង។

ខ-ការដំឡើងឋានន្តរសក្តិថ្នាក់វរសេនីយ៍៖

-វរសេនីយ៍ត្រីបម្រុង វរនាវីត្រីបម្រុង អាចដំឡើងឋានន្តរសក្តិជាវរសេនីយ៍ទោបម្រុង វរនាវីទោបម្រុង លុះត្រាតែសាមីយោធិនបម្រុងនោះ មានអតីតភាពឋានន្តរសក្តិ ៤(បួន) ឆ្នាំ និងបានបំពេញការិយកម្ម១(មួយ)លើក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

-វរសេនីយ៍ទោបម្រុង វរនាវីទោបម្រុង អាចដំឡើងឋានន្តរសក្តិជាវរសេនីយ៍ឯកបម្រុង វរនាវីឯកបម្រុង លុះត្រាតែសាមីយោធិនបម្រុងនោះ មានអតីតភាពឋានន្តរសក្តិ ៥(ប្រាំ) ឆ្នាំ និងបានបំពេញការិយកម្ម១(មួយ)លើក។

ក្នុងក្របខណ្ឌយោធិនបម្រុង ការដំឡើងឋានន្តរសក្តិខ្ពស់បំផុតត្រឹមថ្នាក់វរសេនីយ៍ឯក ឬថ្នាក់វរនាវីឯក។

**មាត្រា២៦.-**

យោធិនបម្រុង ដែលបានបំពេញការងារក្នុងសេវាសកម្ម ការដំឡើងឋានន្តរសក្តិមិនគិតពីការបំពេញការិយកម្មទេ។

ការបំពេញការិយកម្ម ត្រូវលើកលែងចំពោះការដំឡើងឋានន្តរសក្តិ ដល់នាយទាហានបម្រុងថ្នាក់វរសេនីយ៍ដែលមានអតីតភាពពីយោធិនអាជីព។

**មាត្រា២៧.-**

អតីតភាពនៃឋានន្តរសក្តិរបស់យោធិនបម្រុង ត្រូវគិតពីកាលបរិច្ឆេទដែលបានតែងតាំង និងដំឡើងឋានន្តរសក្តិរបស់ខ្លួនក្នុងក្របខណ្ឌយោធិនអាជីព ឬក្របខណ្ឌយោធិនបម្រុង។

**មាត្រា២៨.-**

ការដំឡើងឋានន្តរសក្តិយោធិនបម្រុងត្រូវធ្វើទៅតាមតម្រូវការចាំបាច់របស់ក្រសួងការពារជាតិ។

ក្នុងករណីពិសេសរដ្ឋមន្ត្រីក្រសួងការពារជាតិ អាចតែងតាំង ឬស្នើតែងតាំង និងដំឡើងឋានន្តរសក្តិយោធិនបម្រុង តាមតម្រូវការចាំបាច់។

## ជំពូកទី៧

## ការអញ្ជើញ

**មាត្រា២៩.-**

ក្រសួងការពារជាតិ ធ្វើការអញ្ជើញយោធិនបម្រុង មកបំពេញសកម្មភាពយោធាសម្រាប់រយៈពេលមួយស្របតាមស្ថានភាព និងតាមកាលៈទេសៈតម្រូវ។

ការអញ្ជើញអាចធ្វើឡើងជាបុគ្គល ជាក្រុមសម្រាប់បំពេញសេវាសកម្មក្នុងអង្គភាពយោធិន អាជីពនៃកងយោធពលខេមរភូមិន្ទ ឬការហ្វឹកហ្វឺនបំប៉ន់វិជ្ជាយោធា ការិយកម្ម និងកំណែនទូទៅក្នុងពេលមានសង្គ្រាម។

**មាត្រា៣០.-**

ការអញ្ជើញមកបំពេញសកម្មភាពយោធា ឬការិយកម្មត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

លិខិតអញ្ជើញត្រូវផ្ញើជូនដល់សាមីខ្លួនតាមរយៈអាជ្ញាធរយោធាមូលដ្ឋាន ឬតាមរយៈអាជ្ញាធរឃុំ សង្កាត់ ឬប្រធានអង្គភាព ក្រសួង ស្ថាប័ន រោងចក្រ សហគ្រាស ឬគ្រឹះស្ថានសិក្សាក្នុងរយៈពេលយ៉ាងតិច ៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការមុនថ្ងៃកំណត់ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៣១.–**

យោធិនបម្រុង ដែលទទួលបានការអញ្ជើញមកបម្រើការងារ ក្នុងសកម្មភាពយោធាដូចបានចែង ក្នុងមាត្រា២៩ មាត្រា៣០ខាងលើ ហើយមិនបានមកបង្ហាញខ្លួនតាមកាលកំណត់ដោយគ្មានមូលហេតុ ត្រឹមត្រូវ ត្រូវទទួលការស្តីបន្ទោស ឬទទួលវិន័យតាមបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ ឬទទួលទោសតាមច្បាប់ស្តីពីកាតព្វកិច្ចយោធា។

## ជំពូកទី៨
## ការលុបឈ្មោះចេញពីក្របខណ្ឌយោធិនបម្រុង

**មាត្រា៣២.–**

យោធិនបម្រុងអាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌដោយមូលហេតុ៖

–ដល់អាយុកំណត់

–មានបញ្ហាសុខភាពធ្ងន់ធ្ងរ

–ប្រព្រឹត្តខុសធ្ងន់ធ្ងរពីវិន័យកងទ័ព

–ត្រូវបានតុលាការផ្តន្ទាទោស

–ទទួលមរណភាព។

**មាត្រា៣៣.–**

ការលុបឈ្មោះចេញពីក្របខណ្ឌយោធិនបម្រុង ត្រូវសម្រេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាសរបស់ក្រសួងការពារជាតិ។

## ជំពូកទី៩
## អត្ថប្រយោជន៍

**មាត្រា៣៤.–**

យោធិនបម្រុង ដែលបានបង្កើតស្នាដៃល្អក្នុងពេលបំពេញភារកិច្ច ត្រូវទទួលបានការសរសើរ ការលើកទឹកចិត្ត និងគ្រឿងឥស្សរិយយសតាមសំណើពីរដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា៣៥.–**

ប្រធានអង្គភាព ក្រសួង ស្ថាប័ន រោងចក្រ សហគ្រាស ឬគ្រឹះស្ថានសិក្សា ត្រូវអនុញ្ញាតឲ្យមន្ត្រីរាជការ បុគ្គលិក ដែលបានបញ្ចប់ការងារក្នុងសេវាសកម្ម ការហ្វឹកហ្វឺនបំប៉ន ឬការិយកម្ម ឲ្យចូលបម្រើការងារវិញ ក្នុងក្របខណ្ឌដើមដោយរក្សាឋានៈដូចមុនពេលបំពេញការងារក្នុងសេវាសកម្ម ហើយផ្តល់អាទិភាពក្នុងការពិចារណាដំឡើងថ្នាក់ ឋានន្តរសក្តិ ឬឋានៈ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះចមរេខា៩ចារ៉ាំ១០

910

**មាត្រា៣៦.-**

រយៈពេលបំពេញការងារក្នុងសេវាសកម្មរបស់យោធិនបម្រុងជាមន្ត្រីរាជការស៊ីវិលគិតទាំងរយៈពេលហ្វឹកហ្វឺនបំប៉ន រយៈពេលបំពេញការិយកម្ម ត្រូវបានរាប់បញ្ចូលទុកជាអតីតភាពសម្រាប់ដំឡើងថ្នាក់ ឋានន្តរសក្តិ ឋានៈ និងចូលនិវត្តន៍ក្នុងក្របខណ្ឌដើម។

ពេលបំពេញការងារក្នុងអង្គភាពប្រយុទ្ធនៅសមរភូមិ រយៈពេលត្រូវគិតទ្វេមួយជាពីរ។

ក្នុងករណីពលី មរណៈ បង្កស្លាប់ និងពិការ ក្នុងពេលបំពេញការងារក្នុងសេវាសកម្ម ឬការិយកម្ម យោធិនបម្រុងត្រូវទទួលបានការឧបត្ថម្ភ នូវគោលរបបផ្សេងៗដូចយោធិនអាជីពដែរ។

ករណីនៃការបាត់ខ្លួនក្នុងពេលបំពេញបេសសកម្ម ឬមានសង្គ្រាមយោធិនបម្រុងរូបនោះត្រូវតែដាក់ឲ្យស្ថិតក្នុងស្ថានភាពសេវាសកម្មនៃក្របខណ្ឌយោធិនបម្រុង រហូតដល់មានវត្តមាន ឬមានការចង្អុលភស្តុតាងអំពីមរណភាព។

## ជំពូកទី១០

## អវសានប្បញ្ញត្តិ

**មាត្រា៣៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៨.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០១០

នស/រកត/០៨១០/៦៦០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**លេខៈ ៥៩៤ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៤៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៦០២/១៩១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានប្តូរប្រភេទក្របខ័ណ្ឌជូនមន្ត្រីរាជការ ចំនួន ០៤រូប ទៅក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដូចមានរាយនាមខាងក្រោម ៖

១- លោក **ប៊ុក សារ៉ាន់** កើតថ្ងៃ ០១-តុលា -១៩៥២ ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៦

២- លោក **មុំ ព្រាត** កើតថ្ងៃ ១៨-ឧសភា -១៩៥២ ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ៦

៣- លោកស្រី **សួលី ម៉ារ៉ែស្ស** កើតថ្ងៃ ០៩-ធ្នូ -១៩៥២ ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ១២

៤- លោក **ពៅ សំណាង** កើតថ្ងៃ ១០-មិថុនា -១៩៥២ ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ១៤

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នស/រកត/០៨១០/៦៦៤

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១០*

លេខ: ៥៩៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៤៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន បានបរិច្ចាគធនធាន
ជួយកសាងនៅស្រុកបន្ទាយមាស ខេត្តកំពត

**លោកវរសេនីយ៍ត្រី ស្រ៊ុន ឡាំ អត្តលេខ ៣៥៩៩៣**

នូវ

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១០០៩. ៦៦៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១០

លេខៈ ៥៩៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ីន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៤៩

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំយោធភូមិភាគទី៩ នៃកងទ័ពប្រជាជនវៀតណាម និងថ្នាក់ដឹកនាំក្រុងកិនធឺ
បានជួយកសាងសមិទ្ធផល ជូនប្រជាជន និងបានកសាងស្ពានមិត្តភាព...
មិត្តភាពកម្ពុជា-វៀតណាម បានរួចរាល់ជាស្ថាពរ ៖

១- ឯកឧត្តម **ត្រឹន ភីហូ** TRAN PHI HO

២- ឯកឧត្តម **ង្វៀន តាន់គ្វៀន** NGUYEN TAN QUYEN

នូវ

**គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
**នរោត្តម សីហមុនី**

ពរល.១០០៩.៦៦៤

លេខ: ៥៩៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ សីហា ឆ្នាំ២០១០
[illegible]ធិការ[illegible]រាជរដ្ឋាភិបាល

[illegible] ជិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៥០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយនគរបាលជាតិ ចំនួន ១១ រូប នៃក្រសួងមហាផ្ទៃ ដែលបានខិតខំបំរើជាតិ សាសនា ព្រះមហាក្សត្រ :

នូវ

- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** ជូនចំពោះ :

១-លោកឧត្តមសេនីយ៍ទោ **នៅ លក្ខណា** ០៤៣២

២-លោកឧត្តមសេនីយ៍ត្រី **សែន សម្បត្តិ** ០៧៤៨

៣-លោកឧត្តមសេនីយ៍ត្រី **ឈៀង សារ៉ាត** ០៧៥០

៤-លោកឧត្តមសេនីយ៍ត្រី **អ៊ុំ សុខឃី** ០៧៥២

៥-លោកវរសេនីយ៍ទោ **គួច ហុងជៀក** ២៩៦៦៨

- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** ជូនចំពោះ :

១-លោកឧត្តមសេនីយ៍ត្រី **សោម ឡេង** ០១៥២៧

២-លោកវរសេនីយ៍ឯក **ខុង លី** ៦៤២៦៦

៣-លោកវរសេនីយ៍ទោ **ធូ សារឿន** ០១២០៤

៤-លោកវរសេនីយ៍ទោ **ម៉ែន សំអាន** ០១២០៩

៥-លោកអនុសេនីយ៍ទោ **ចេង ខេង** ៦៤០៤២

៦-លោកព្រិន្ទបាលទោ **គាំ បុណា** ៦៦០០៨

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.១០០៩.៦៦៥

លេខៈ ៥៩៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[illegible] ជិនកេន

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១០

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៥១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហាគាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

លោកជំទាវ ញឹម សុខាល័យ

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៧.២០០៩.៦៦៦

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១០

លេខៈ ៥៩១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៥២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រទានព្រះរាជទាន**

**ចំពោះ**

នាយនគរបាលជាតិ និងសប្បុរសជនបានបរិច្ចាគធនធាន ចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធសង្គមជាតិ និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ នៅស្រុកបាណន់ ខេត្តបាត់ដំបង ៖

**ដូច**

**ក- គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍ ចំពោះ ៖**

១- ឯកឧត្តម អ៊ុច សុខុន
២- ឯកឧត្តម ងួន សុធាវី
៣- លោកឧត្តមសេនីយ៍ទោ ផៃ ស៊ីណារិទ្ធ អត្តលេខ ០២៣៣
៤- លោកឧត្តមសេនីយ៍ទោ យុន សំបូរ អត្តលេខ ០៦៩៣

**ខ- គ្រឿងឥស្សរិយយសសុវត្ថារា ថ្នាក់មហាសេរីវឌ្ឍន៍ ចំពោះ ៖**

១- ឯកឧត្តម ទេស ហ៊ាញ
២- លោកជំទាវ គឹម ហេង

**គ- គ្រឿងឥស្សរិយយសសេនាជ័យសិទ្ធិ ចំពោះ ៖**

១- លោកឧត្តមសេនីយ៍ត្រី ទៀង សារ៉ាក់ អត្តលេខ ០៧៥០
២- លោកឧត្តមសេនីយ៍ត្រី ឯម វិចិត្រ អត្តលេខ ០៤៤៤៥
៣- លោកឧត្តមសេនីយ៍ត្រី ជុំ ហេង អត្តលេខ ០៦២២១
៤- លោកឧត្តមសេនីយ៍ត្រី ម៉ុក វណ្ណា អត្តលេខ ០៤៧៧៧
៥- លោកវរសេនីយ៍ឯក សៀង សេន អត្តលេខ ០១៤១៣
៦- លោកវរសេនីយ៍ឯក ប៉ាង ណាវ៉េន អត្តលេខ ០១៣៩៣

**ឃ- គ្រឿងឥស្សរិយយសសុវត្ថារា ថ្នាក់មហាសេនា ចំពោះ ៖**

១-លោកឧត្តមសេនីយ៍ត្រី សុខ វាសនា អត្តលេខ ០១៤១១
២- លោក សាន ហាក់
៣- លោក ឈាន គឿន
៤- លោក ជុំ ញ៉ី
៥- លោក ប៊ុត សំបូរ
៦- លោក សុខ លីហួត
៧- លោក កែម សារិន
៨- លោកវរសេនីយ៍ទោ ងួន ស្រេង អត្តលេខ ០៣៧៨៨
៩- លោក នេត ស៊ីថុន
១០- លោក ស្លួត សំបុណ្យ
១១- លោក សៅ ប៊ុនរិទ្ធិ
១២- លោក ណាច ទ្រី

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ខ- **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍ ចំពោះ ៖**

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក សុខ ផល អត្តលេខ ០០៥១
២- ឯកឧត្តម រោម ហាក់
៣- លោកឧត្តមសេនីយ៍ត្រី ប៊ុន ថាវណ្ណ អត្តលេខ ០១០១៦
៤- លោកស្រី ទេព រ៉ូហ្សាន់
៥- លោក ឡាំង ផុងមីង
៦- លោកស្រី សៀង ស៊ីពោធិ
៧- លោកស្រី ឯម សុជាតិ
៨- លោក ជាង ពៅ
៩- លោក សោម សោភ័ណ

ច- **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់មហាសេនា ចំពោះ ៖**

១- លោក ឌឹម វ៉ា
២- លោក សំ វីរៈ
៣- លោក អ៊ុក ហៃសិលា
៤- លោក ម៉ិញ សុធីវណ្ណ
៥- លោក វ៉ាត់ ស៊ូឌីណា
៦- លោក ហ៊ី ព្រូ
៧- លោក អ៊ុក ច័ន្ទកុសល
៨- លោក ពៅ សំអុន
៩- លោក អ៊ុច សុជាវត្ថ
១០- លោក ណុប នរិន្ទ
១១- លោក គួច ហុងជៀក
១២- លោក គាន គឹមលាង
១៣- លោក លី ឡាយ
១៤- លោក ហុង លី
១៥- លោក អ៊ិន សុន្ទរា
១៦- លោក ដួង ច័ន្ទអម្រិត
១៧- លោក ម៉ិល សុផល
១៨- លោកស្រី វង្ស និស្ស័យ
១៩- លោក ហេង ឆាត
២០- លោក នួន សុវណ្ណា

ឆ- **គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន ចំពោះ ៖**

១- លោកឧត្តមសេនីយ៍ត្រី គឹង វណ្ណៈ អត្តលេខ ៦៤៥៥៥
២- លោកឧត្តមសេនីយ៍ត្រី សៀង យូជាវ៉ាត់ អត្តលេខ ៥៤០៣៧
៣- លោ ទូច ឆាយ
៤- លោ យ៉ិន សារឿន

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រ.ល. ១០០៩.៦៦៧ **នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១០

**លេខ: ៥៩០ ច.ល**

**បានឃើញ ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ សីហា ឆ្នាំ២០១០

**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

**ស៊ុន ជិនគេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៥៣

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ១៦២ រូប បានខិតខំប្រឹងប្រែងបំពេញភារកិច្ច ថែរក្សា ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងស្ថេរភាពសង្គម ដើម្បីបំរើផលប្រយោជន៍ របស់ប្រទេសជាតិ និងប្រជាពលរដ្ឋបានល្អប្រសើរ ៖

នូវ

**ក - គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍**

១ លោកឧត្តមសេនីយ៍ឯក ផ្លុង គឹមធុន អត្តលេខ ០០៦៤
២ លោកឧត្តមសេនីយ៍ឯក ឈិម សាក់ក់ អត្តលេខ ០១៤៤
៣ លោកឧត្តមសេនីយ៍ឯក គៀត ច័ន្ទថាវិទ្ធ អត្តលេខ ០២៤៧

**ខ - គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ**

១ ឯកឧត្តមនាយឧត្តមសេនីយ៍ ឯម សំអាន អត្តលេខ ០០១
២ លោកឧត្តមសេនីយ៍ទោ ជា សុគន្ធា អត្តលេខ ០១៥២៨
៣ លោកឧត្តមសេនីយ៍ត្រី ង៉ិល វណ្ណធឿន អត្តលេខ ០១០២៧
៤ លោកឧត្តមសេនីយ៍ត្រី យឹម ស៊ីមុនី អត្តលេខ ០៣៦២៧
៥ លោកឧត្តមសេនីយ៍ត្រី ម៉េង ងួនលឹម អត្តលេខ ០២១៨១
៦ លោកឧត្តមសេនីយ៍ត្រី កែប សុវណ្ណដារ៉ា អត្តលេខ ០១៩៧៧
៧ លោកឧត្តមសេនីយ៍ត្រី ហាក់ គឹមរ៉ុង អត្តលេខ ០៩០៥
៨ លោកឧត្តមសេនីយ៍ត្រី គាត សុមនា អត្តលេខ ០១៩៦០
៩ លោកឧត្តមសេនីយ៍ត្រី ប៉ោង សុគន្ធា អត្តលេខ ០១០៨៩
១០ លោកឧត្តមសេនីយ៍ត្រី រស់ សាផល អត្តលេខ ០៩៨១
១១ លោកឧត្តមសេនីយ៍ត្រី ស៊ិន រ៉្សី អត្តលេខ ០៦៤៩
១២ លោកឧត្តមសេនីយ៍ត្រី ជា សូផាត អត្តលេខ ០៥៣៤
១៣ លោកឧត្តមសេនីយ៍ត្រី ស៊ិន សារិទ្ធ អត្តលេខ ០៥៣៦

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

| | | | | |
|---|---|---|---|---|
| ១៤ | លោកឧត្តមសេនីយ៍ត្រី | ទៀង | សារ៉ាត់ | អត្តលេខ ០៧៥០ |
| ១៥ | លោកវរសេនីយ៍ឯក | អ៊ុំ | ចាន់កុសល | អត្តលេខ ០៥០១១ |
| ១៦ | លោកវរសេនីយ៍ឯក | សុខ | សុផាត | អត្តលេខ ០១៧៤៣ |
| ១៧ | លោកវរសេនីយ៍ឯក | ថាប់ | សារិទ្ធ | អត្តលេខ ០៥៣៧ |
| ១៨ | លោកវរសេនីយ៍ឯក | រ៉ែយ | ធឿន | អត្តលេខ ៥៦០៣៤ |
| ១៩ | លោកវរសេនីយ៍ឯក | សូ | ប៊ុននឿន | អត្តលេខ ០៤២៥ |
| ២០ | លោកវរសេនីយ៍ឯក | ប៉ុល | ភិធេយ្យ | អត្តលេខ ០៣៦២០ |
| ២១ | លោកវរសេនីយ៍ឯក | ស៊ី | គិរី | អត្តលេខ ០៤៧២ |
| ២២ | លោកវរសេនីយ៍ឯក | គឹម | សុខុន | អត្តលេខ ០៤៦៩ |
| ២៣ | លោកវរសេនីយ៍ឯក | រស់ | ប៊ុនណាន | អត្តលេខ ០៣០១០ |
| ២៤ | លោកវរសេនីយ៍ឯក | ឆាយ | ភន | អត្តលេខ ០៣៧៣៣ |
| ២៥ | លោកវរសេនីយ៍ឯក | ឱ | ហ៊ាង | អត្តលេខ ០១៦០៥ |
| ២៦ | លោកវរសេនីយ៍ឯក | កែវ | សុគន្ធ | អត្តលេខ ០១៦០៩ |
| ២៧ | លោកវរសេនីយ៍ឯក | ប៊ូ | ផល | អត្តលេខ ០៧៦៤ |
| ២៨ | លោកវរសេនីយ៍ឯក | អ៊ុំ | ភី | អត្តលេខ ០២០៣៧ |
| ២៩ | លោកវរសេនីយ៍ឯក | នូ | សារ៉ា | អត្តលេខ ០២០១៧ |
| ៣០ | លោកវរសេនីយ៍ឯក | សុខ | ចាន់ជន | អត្តលេខ ០៤៥៩ |
| ៣១ | លោកវរសេនីយ៍ឯក | ទៀង | សៅរេតន៍ | អត្តលេខ ០៣៤៨៦ |

**គ - គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់សេនា**

| | | | | |
|---|---|---|---|---|
| ១ | លោកឧត្តមសេនីយ៍ឯក | ហួន | ចន្ទកក្កដា | អត្តលេខ ៥៤៩២៥ |
| ២ | លោកឧត្តមសេនីយ៍ទោ | ឯក | មនោសែន | អត្តលេខ ៦១៧១៨ |
| ៣ | លោកឧត្តមសេនីយ៍ត្រី | អ៊ុកគឹម | កាម៉ារាជ | អត្តលេខ ០២១៤៤ |
| ៤ | លោកឧត្តមសេនីយ៍ត្រី | ឡាយ | សំអាត | អត្តលេខ ០៦៩៨៤ |
| ៥ | លោកឧត្តមសេនីយ៍ត្រី | ជុំ | ហេង | អត្តលេខ ០៦២២១ |
| ៦ | លោកឧត្តមសេនីយ៍ត្រី | ឌី | វិជ្ជា | អត្តលេខ ០១២៧៨ |
| ៧ | លោកឧត្តមសេនីយ៍ត្រី | ហាស់ | ម៉េងឡុង | អត្តលេខ ៦៣៩៩៩ |
| ៨ | លោកឧត្តមសេនីយ៍ត្រី | នៅ | សុផា | អត្តលេខ ០១៣៨៣ |
| ៩ | លោកឧត្តមសេនីយ៍ត្រី | លឹម | ឡុង | អត្តលេខ ០៩៦៥ |
| ១០ | លោកឧត្តមសេនីយ៍ត្រី | ជា | ប៊ុនថុល | អត្តលេខ ០៦៣៧ |
| ១១ | លោកឧត្តមសេនីយ៍ត្រី | ជា | ឡាយ | អត្តលេខ ០១៣៨៦ |
| ១២ | លោកឧត្តមសេនីយ៍ត្រី | សោម | ឡេង | អត្តលេខ ០១៥២៧ |
| ១៣ | លោកឧត្តមសេនីយ៍ត្រី | ហៃ | យូណែល | អត្តលេខ ៥៤៨៦៣ |

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

| | | | |
|---|---|---|---|
| ១៤ លោកឧត្តមសេនីយ៍ត្រី | សេង | វណ្ណៈ | អត្តលេខ ០២១៧៨ |
| ១៥ លោកឧត្តមសេនីយ៍ត្រី | ចាន់ | ស៊ីថា | អត្តលេខ ០១២៥០ |
| ១៦ លោកឧត្តមសេនីយ៍ត្រី | អ៊ុន | ស៊ីថា | អត្តលេខ ០៩១១ |
| ១៧ លោកវរសេនីយ៍ឯក | សឿង | អូន | អត្តលេខ ០៦៤០ |
| ១៨ លោកវរសេនីយ៍ឯក | កេង | សុគន្ធ | អត្តលេខ ០២២៩៧ |
| ១៩ លោកវរសេនីយ៍ឯក | ស៊ិន | រដ្ឋា | អត្តលេខ ៥៥៣០៩ |
| ២០ លោកវរសេនីយ៍ឯក | ម៉ិញ | សុជីវណ្ណ | អត្តលេខ ០៧០២ |
| ២១ លោកវរសេនីយ៍ឯក | សៀង | សម្បត្តិ | អត្តលេខ ០៦៨៩ |
| ២២ លោកវរសេនីយ៍ឯក | ស | ថេង | អត្តលេខ ០១០៩៦ |
| ២៣ លោកវរសេនីយ៍ឯក | ម៉ឹង | វណ្ណារ៉ា | អត្តលេខ ០៤៨៧២ |
| ២៤ លោកវរសេនីយ៍ឯក | ប៊ុន | ស៊ីផៃ | អត្តលេខ ០៦៥៤ |
| ២៥ លោកវរសេនីយ៍ឯក | សំ | ពិសី | អត្តលេខ ០៦៥៥ |
| ២៦ លោកវរសេនីយ៍ឯក | អ៊ុក | ច័ន្ទតារា | អត្តលេខ ០១៣១០ |
| ២៧ លោកវរសេនីយ៍ឯក | ប្រាយ | សុន | អត្តលេខ ០៤៧៦ |
| ២៨ លោកវរសេនីយ៍ឯក | អ៊ុំ | គឹមសុង | អត្តលេខ ០៦៣៥ |
| ២៩ លោកវរសេនីយ៍ឯក | ស៊ឹម | ហ៊ុំ | អត្តលេខ ០៦០២ |
| ៣០ លោកវរសេនីយ៍ឯក | ហេក | ជិនលីម | អត្តលេខ ០៥៩៤ |
| ៣១ លោកវរសេនីយ៍ឯក | ទិត្យ | ប៊ុនណា | អត្តលេខ ០៦៩៦ |
| ៣២ លោកវរសេនីយ៍ឯក | ឡុង | យឿន | អត្តលេខ ០១២៧៤ |
| ៣៣ លោកវរសេនីយ៍ឯក | កែវ | សុវណ្ណ | អត្តលេខ ០៦៧៨៩ |
| ៣៤ លោកវរសេនីយ៍ឯក | វ៉ែន | សុគា | អត្តលេខ ០១៤២២ |
| ៣៥ លោកវរសេនីយ៍ឯក | នូ | សារ៉ាវិទ្ធ | អត្តលេខ ០៧៦០ |
| ៣៦ លោកវរសេនីយ៍ឯក | ហែ | សុវណ្ណ | អត្តលេខ ០៧៥៨ |
| ៣៧ លោកវរសេនីយ៍ឯក | យឹម | សុវណ្ណ | អត្តលេខ ០៦៤៤ |
| ៣៨ លោកវរសេនីយ៍ឯក | យឹត | សុភ័ក្រ្ត | អត្តលេខ ០៦៨៦ |
| ៣៩ លោកវរសេនីយ៍ឯក | អ៊ុក | ហៃសីឡា | អត្តលេខ ១៥៧៣៣ |
| ៤០ លោកវរសេនីយ៍ឯក | អ៊ាន | សុត្ថារ | អត្តលេខ ០៩០១ |
| ៤១ លោកវរសេនីយ៍ឯក | ឃួន | សូផន | អត្តលេខ ០៧៥០៧ |
| ៤២ លោកវរសេនីយ៍ឯក | ស៊ិន | ប៊ុនថន | អត្តលេខ ០២២៨៤ |
| ៤៣ លោកវរសេនីយ៍ឯក | គុប | ចាន់ថន | អត្តលេខ ០១០៤៦ |
| ៤៤ លោកវរសេនីយ៍ឯក | អែល | សំនាង | អត្តលេខ ០១៥០៩ |
| ៤៥ លោកវរសេនីយ៍ឯក | ជិន | វិទ្យា | អត្តលេខ ០២៥៩២ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | |
|---|---|---|---|
| ៤៦ លោកវរសេនីយ៍ឯក | ស្រី | សុវណ្ណា | អត្តលេខ ០៣២៤០ |
| ៤៧ លោកវរសេនីយ៍ឯក | បាន | ហេង | អត្តលេខ ០១៦១៤ |
| ៤៨ លោកវរសេនីយ៍ឯក | ប៊ិច | សោមសាខន | អត្តលេខ ០២០៣៤ |
| ៤៩ លោកវរសេនីយ៍ឯក | យិន | ចំណាន | អត្តលេខ ១២១៦៩ |
| ៥០ លោកវរសេនីយ៍ឯក | ច្រឹង | ផល្លី | អត្តលេខ ០២០៣៥ |
| ៥១ លោកវរសេនីយ៍ឯក | គួច | យ៉ុន | អត្តលេខ ០៣៨៣៨ |
| ៥២ លោកវរសេនីយ៍ឯក | អ៊ុក | វណ្ណធី | អត្តលេខ ០២២៣២ |
| ៥៣ លោកវរសេនីយ៍ទោ | លាន | សូ | អត្តលេខ ០៥៨២២ |

**ឃ - គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់អស្សឫទ្ធិ**

| | | | |
|---|---|---|---|
| ១ លោកឧត្តមសេនីយ៍ត្រី | ចាន់ | វ៉ាន់ធឿន | អត្តលេខ ០២១៥៩ |
| ២ លោកវរសេនីយ៍ឯក | តាន់ | សុរិដ្ឋា | អត្តលេខ ០៥៥៥៥ |
| ៣ លោកវរសេនីយ៍ឯក | គៀង | ចាន់តួ | អត្តលេខ ៦៧៨៩៥ |
| ៤ លោកវរសេនីយ៍ឯក | ប៉ែន | វណ្ណា | អត្តលេខ ០១០៧៨ |
| ៥ លោកវរសេនីយ៍ឯក | ម៉ុក | សាវ៉ាត | អត្តលេខ ០៨៧៩ |
| ៦ លោកវរសេនីយ៍ឯក | យី | វណ្ណះ | អត្តលេខ ០៦៩៩ |
| ៧ លោកវរសេនីយ៍ឯក | អែ | សារឹម | អត្តលេខ ០៧៥៤ |
| ៨ លោកវរសេនីយ៍ឯក | អែ | ឥទ្ធីឫទ្ធិ | អត្តលេខ ០៥២៦៩ |
| ៩ លោកវរសេនីយ៍ឯក | រស់ | ឧស្សាហ៍ | អត្តលេខ ៦៥៨៨៨ |
| ១០ លោកវរសេនីយ៍ឯក | ព្រំ | វុត្ថា | អត្តលេខ ០១២៦៥ |
| ១១ លោកវរសេនីយ៍ឯក | ខៀវ | សំណាង | អត្តលេខ ០១៣០៥ |
| ១២ លោកវរសេនីយ៍ឯក | ជា | សំបូរ | អត្តលេខ ០៦៧៤៩ |
| ១៣ លោកវរសេនីយ៍ឯក | ហ៊ិល | សម្បត្តិ | អត្តលេខ ០៣៦២៧ |
| ១៤ លោកវរសេនីយ៍ឯក | ហៀក | វុទ្ធី | អត្តលេខ ០២១៣៨ |
| ១៥ លោកវរសេនីយ៍ឯក | ឈុន | ចាន់សុខា | អត្តលេខ ០៦៩៨ |
| ១៦ លោកវរសេនីយ៍ឯក | សរ | វ៉ាន់ថុន | អត្តលេខ ០២៩៥៩ |
| ១៧ លោកវរសេនីយ៍ឯក | នួន | ថាន | អត្តលេខ ០៩៧៩ |
| ១៨ លោកវរសេនីយ៍ឯក | កែម | សារិន | អត្តលេខ ៥៧៨៨១ |
| ១៩ លោកវរសេនីយ៍ឯក | អ៊ុំ | ប៊ុនថន | អត្តលេខ ០១២៨០ |
| ២០ លោកវរសេនីយ៍ឯក | ម៉ៅ | ម៉ុន | អត្តលេខ ០៥១០៦ |
| ២១ លោកវរសេនីយ៍ឯក | ខ្លូត | តារា | អត្តលេខ ០១១៤៩ |
| ២២ លោកវរសេនីយ៍ឯក | គង់ | មនោ | អត្តលេខ ១៥៨៣១ |
| ២៣ លោកវរសេនីយ៍ឯក | ធឹង | នឿន | អត្តលេខ ០១៩៦១ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះរាជវាំង

| | | | |
|---|---|---|---|
| ២៤ លោកវរសេនីយ៍ឯក | នាង | រិទ្ធ | អត្តលេខ ៦៥៧៧៧ |
| ២៥ លោកវរសេនីយ៍ឯក | សុង | សាក់ | អត្តលេខ ៣៧០៨០ |
| ២៦ លោកវរសេនីយ៍ឯក | ជួង | សំរិទ្ធ | អត្តលេខ ០៥២១៦ |
| ២៧ លោកវរសេនីយ៍ឯក | ម៉ៃ | សាវុធ | អត្តលេខ ១២១៧៤ |
| ២៨ លោកវរសេនីយ៍ឯក | រស់ | សុខធឿន | អត្តលេខ ០៧៧៣ |
| ២៩ លោកវរសេនីយ៍ឯក | សុខ | លីណា | អត្តលេខ ០១៣៣៥ |
| ៣០ លោកវរសេនីយ៍ឯក | ខូវ | លី | អត្តលេខ ៦៤២៦៦ |
| ៣១ លោកវរសេនីយ៍ឯក | លី | ដាវុធ | អត្តលេខ ៥៤៤៧៧ |
| ៣២ លោកវរសេនីយ៍ឯក | លីវ | សុផាណារិទ្ធ | អត្តលេខ ៥៥៤១៥ |
| ៣៣ លោកវរសេនីយ៍ឯក | សេក | រដ្ឋា | អត្តលេខ ០១១៧១ |
| ៣៤ លោកវរសេនីយ៍ឯក | អ៊ូ | មុន្នីរ័ត្ន | អត្តលេខ ១២៩៧៣ |
| ៣៥ លោកវរសេនីយ៍ឯក | សួស | សុភាព | អត្តលេខ ៦២៧៤០ |
| ៣៦ លោកវរសេនីយ៍ឯក | យន់ | លីនណៃ | អត្តលេខ ៥៧២៦៧ |
| ៣៧ លោកវរសេនីយ៍ឯក | ទិត | សារី | អត្តលេខ ០១៧៣ |
| ៣៨ លោកវរសេនីយ៍ឯក | ជួប | ពោធិរិទ្ធ | អត្តលេខ ០៧៨៥ |
| ៣៩ លោកវរសេនីយ៍ឯក | សៀង | សេន | អត្តលេខ ០១៤១៣ |
| ៤០ លោកវរសេនីយ៍ឯក | យូ | វីរៈ | អត្តលេខ ៦៧៥៨៦ |
| ៤១ លោកវរសេនីយ៍ឯក | ឡៀប | វណ្ណារិទ្ធ | អត្តលេខ ០១០២៤ |
| ៤២ លោកវរសេនីយ៍ឯក | អាំ | ថន | អត្តលេខ ១២៧៧០ |
| ៤៣ លោកវរសេនីយ៍ឯក | អ៊ុក | វណ្ណា | អត្តលេខ ០១០០៦ |
| ៤៤ លោកវរសេនីយ៍ឯក | អ៊ឹម | វិសាន | អត្តលេខ ០១០៣១ |
| ៤៥ លោកវរសេនីយ៍ឯក | ហួរ | សានី | អត្តលេខ ០១០២៩ |
| ៤៦ លោកវរសេនីយ៍ឯក | ម៉ៅ | ច័ន្ទមុនីរិទ្ធ | អត្តលេខ ៥៤០៤៥ |
| ៤៧ លោកវរសេនីយ៍ឯក | ហេង | សុត្ថា | អត្តលេខ ០១០៣៦ |
| ៤៨ លោកវរសេនីយ៍ឯក | គង់ | សារី | អត្តលេខ ០៧៤៦២ |
| ៤៩ លោកវរសេនីយ៍ឯក | អោម | សារ៉ន់ | អត្តលេខ ០២២៧៨ |
| ៥០ លោកវរសេនីយ៍ឯក | លឹម | ដាវុធ | អត្តលេខ ០៣៥១៨ |
| ៥១ លោកវរសេនីយ៍ឯក | ប៉ូ | មុត | អត្តលេខ ០៣៦២៣ |
| ៥២ លោកវរសេនីយ៍ឯក | ខៀវ | ស៊ីណាត | អត្តលេខ ០២២៨២ |
| ៥៣ លោកវរសេនីយ៍ឯក | កាន់ | ផា | អត្តលេខ ០៥០៤៣ |
| ៥៤ លោកវរសេនីយ៍ឯក | គាំ | សុខាន់ | អត្តលេខ ០៦២៨៧ |
| ៥៥ លោកវរសេនីយ៍ឯក | សរ | ចន្ថា | អត្តលេខ ០២៤១២ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

| | | | |
|---|---|---|---|
| ៥៦ លោកវរសេនីយ៍ឯក | លី | ឡាយ៉ារិទ្ធិ | អត្តលេខ ០៧៤៥៨ |
| ៥៧ លោកវរសេនីយ៍ឯក | លី | ឡាយ | អត្តលេខ ០៣៦២៦ |
| ៥៨ លោកវរសេនីយ៍ឯក | ទិត្យ | គឹមអិន | អត្តលេខ ០២២៧៥ |
| ៥៩ លោកវរសេនីយ៍ឯក | ឡាយ | ប៊ុនថន | អត្តលេខ ០៣៦៩៥ |
| ៦០ លោកវរសេនីយ៍ឯក | ប៉ុល | ផាន់ណា | អត្តលេខ ០៦៥១៧ |
| ៦១ លោកវរសេនីយ៍ឯក | ប្រុក | ជា | អត្តលេខ ០២២៨៦ |
| ៦២ លោកវរសេនីយ៍ឯក | ម៉ៅ | សំបុណ្យ | អត្តលេខ ០៣០៧៥ |
| ៦៣ លោកវរសេនីយ៍ឯក | ហេង | កេងសួគ៌ | អត្តលេខ ០៨៩៣ |
| ៦៤ លោកវរសេនីយ៍ឯក | គួន | ផល | អត្តលេខ ០១៥០៦ |
| ៦៥ លោកវរសេនីយ៍ឯក | សឺន | សារី | អត្តលេខ ១៣២៨៤ |
| ៦៦ លោកវរសេនីយ៍ឯក | ហ៊ិន | សុផល | អត្តលេខ ០៩១៣ |
| ៦៧ លោកស្រីវរសេនីយ៍ឯក | សន | សុផល | អត្តលេខ ០៩៧៣៨ |
| ៦៨ លោកវរសេនីយ៍ឯក | ហេង | សម្បត្តិ | អត្តលេខ ០៣២៣៥ |
| ៦៩ លោកវរសេនីយ៍ឯក | កុល | ផាលី | អត្តលេខ ០១៩៨០ |
| ៧០ លោកវរសេនីយ៍ឯក | អ៊ុំ | អមរា | អត្តលេខ ០៥៧៧២ |
| ៧១ លោកវរសេនីយ៍ឯក | គង់ | សំអូន | អត្តលេខ ០៣៧៧៩ |
| ៧២ លោកវរសេនីយ៍ឯក | លន | ណាឡេម | អត្តលេខ ០១៧១៣ |
| ៧៣ លោកវរសេនីយ៍ឯក | កែវ | ហួរ | អត្តលេខ ២០៥១២ |
| ៧៤ លោកវរសេនីយ៍ឯក | ពេជ្រ | យ៉ុន | អត្តលេខ ០១៣១៥ |
| ៧៥ លោកស្រីវរសេនីយ៍ទោ | នៃ | សំណាង | អត្តលេខ ០៣៤២៦ |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣.រ.ល. ១០០៩.៦៦៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១០*

លេខៈ ៥៨៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៥៤

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយទាហាន ចំនួន ២២ រូប នៃវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល មានស្នាដៃល្អ
និងគុណបំណាច់ខ្ពស់ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ :

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ៖

| | | |
|---|---|---|
| ឧត្ដមសេនីយ៍ទោ | លន់ សុខុន | អត្តលេខ ០០០២៥៨ |

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ ៖

| | | |
|---|---|---|
| ១-ឧត្ដមសេនីយ៍ត្រី | កែវ ចំនួនតារា | អត្តលេខ ០០០៦២៧ |
| ២-ឧត្ដមសេនីយ៍ត្រី | នឹម ម៉ាលា | អត្តលេខ ០១៩៧៥៥ |
| ៣-ឧត្ដមសេនីយ៍ត្រី | សែម សុខុន | អត្តលេខ ០០០៦២៨ |
| ៤-ឧត្ដមសេនីយ៍ត្រី | គួក លន់ | អត្តលេខ ០០០៦២៩ |
| ៥-ឧត្ដមសេនីយ៍ត្រី | សរកែវ រ៉ាវឌ្ឍ | អត្តលេខ ០០១៧៣៥ |
| ៦-ឧត្ដមសេនីយ៍ត្រី | ប៊ុន តារី | អត្តលេខ ០១៤៣៨១ |
| ៧-ឧត្ដមសេនីយ៍ត្រី | សា ចាន់ណា | អត្តលេខ ០០៣២១៥ |

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ ៖

| | | |
|---|---|---|
| ១-វរសេនីយ៍ឯក | មិន សុខុន | អត្តលេខ ០០៨៦០៣ |
| ២-វរសេនីយ៍ឯក | ម៉ែត សួន | អត្តលេខ ០០១៧៧៧ |
| ៣-វរសេនីយ៍ឯក | ជួប សារ៉េត | អត្តលេខ ០០៨៤៨៩ |
| ៤-វរសេនីយ៍ឯក | ហ៊ីង គង់ | អត្តលេខ ០០៨៤៩៥ |
| ៥-វរសេនីយ៍ទោ | អ៊ុំ ចំនួនថន | អត្តលេខ០១៤៣៤១ |

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ ៖

| | | |
|---|---|---|
| ១-វរសេនីយ៍ឯក | ស្វាយ កាម៉ុល | អត្តលេខ ០០៨៥៥២ |
| ២-វរសេនីយ៍ឯក | សាយ សារ៉ាំ | អត្តលេខ ០០៨៥៦១ |
| ៣-វរសេនីយ៍ទោ | ចាន់ ថារិទ្ធ | អត្តលេខ ០១៩៥៤៧ |

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ ៖

| | | |
|---|---|---|
| ១-វរសេនីយ៍ឯក | នួច ឈឿន | អត្តលេខ ០០៨៤៩២ |
| ២-វរសេនីយ៍ឯក | គឹម ឧត្ដរ៍ | អត្តលេខ ០១៩៨១៨ |
| ៣-វរសេនីយ៍ទោ | ហេង សារុន | អត្តលេខ ០០៨៥៦៦ |
| ៤-វរសេនីយ៍ទោ | យស សំបូរ | អត្តលេខ ០១៩៥៥៥ |
| ៥-វរសេនីយ៍ទោ | ស្រី ឈុន្នី | អត្តលេខ ០១៤៣៣១ |
| ៦-វរសេនីយ៍ត្រី | គង សាគ | អត្តលេខ ០៣២១៩៤ |

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ

នរោត្ដម សីហមុនី

៣រល ១០០៩.៦៦៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១០

ច.ល
ដើម្បីចម្លងចែក
ឆ្នាំ២០១០
ប្រធានរដ្ឋបាល

ឈិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៥៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្លាស់ឯកឧត្តម **ខៀវ ស៊ីសុដា** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រតិភូអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការយូណេស្កូ ឲ្យវិលត្រឡប់មកបំពេញបេសកកម្មក្នុងប្រទេសវិញ។

**មាត្រា ២:** ត្រូវបានតែងតាំងឯកឧត្តម **នុត ណារ៉ាង** ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រតិភូអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការយូណេស្កូ ជំនួសឯកឧត្តម **ខៀវ ស៊ីសុដា** ដែលត្រូវវិលត្រឡប់មកបំពេញបេសកកម្មក្នុងប្រទេសវិញ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ.ល.១០០៩.៦៧០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១០

លេខៈ ៥៩៧ ច.ល

ថតចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យ លេខ ១៦អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- បានឃើញអនុក្រឹត្យ លេខ ២៦អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១ -**

ត្រូវផ្ទេរពីថវិកាជាតិទៅគណនីមូលនិធិឃុំ សង្កាត់ សម្រាប់ថេរវេលាបីឆ្នាំ ដោយកំណត់ជាភាគរយនៃចំណូលចរន្តរបស់ថវិកាជាតិ ដូចខាងក្រោម ៖

- ឆ្នាំថវិកា២០១១ : មិនត្រូវតិចជាង២,៨០% នៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១០
- ឆ្នាំថវិកា២០១២ : មិនត្រូវតិចជាង២,៨០% នៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១១
- ឆ្នាំថវិកា២០១៣ : មិនត្រូវតិចជាង២,៨០% នៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១២

**មាត្រា ២-**

ធនធានមូលនិធិសរុបដែលបានមកពីការចូលរួមរបស់ថវិកាជាតិ ដូចដែលមានកំណត់ក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ការចូលរួមពីជំនួយឥតសំណង និងការខ្ចីដែលបានមកពីដៃគូអភិវឌ្ឍន៍នានា ត្រូវបែងចែកជាពីរសមាសភាគ ហើយត្រូវបានកំណត់សមាមាត្រសម្រាប់រយៈពេលពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ ចំពោះសមាសភាគនីមួយៗ ដូចខាងក្រោម ៖

| ឆ្នាំថវិកា | សមាសភាគរដ្ឋបាលទូទៅ | សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន |
|---|---|---|
| ឆ្នាំថវិកា២០១១ | មិនត្រូវច្រើនជាងមួយភាគបី | មិនត្រូវតិចជាងពីរភាគបី |
| ឆ្នាំថវិកា២០១២ | មិនត្រូវច្រើនជាងមួយភាគបី | មិនត្រូវតិចជាងពីរភាគបី |
| ឆ្នាំថវិកា២០១៣ | មិនត្រូវច្រើនជាងមួយភាគបី | មិនត្រូវតិចជាងពីរភាគបី |

**មាត្រា ៣-**

ធនធាននៃសមាសភាគរដ្ឋបាលទូទៅ ត្រូវបានប្រើប្រាស់សម្រាប់ចំណាយទាំងឡាយដូចបានចែងក្នុងកថាខ័ណ្ឌទី២ មាត្រា១៥ នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់ និងសម្រាប់ចំណាយឧបត្ថម្ភដល់មន្ត្រីភូមិតាមរបបកំណត់ជាធរមាន ។

ធនធាននៃសមាសភាគរដ្ឋបាលទូទៅរួមមាន ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាល ចំណាយសម្រាប់ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាឃុំ សង្កាត់ និង មន្ត្រីភូមិ ។

ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាល ត្រូវបានគណនាដោយយកធនធាននៃសមាសភាគរដ្ឋបាលទូទៅដកចេញនូវចំណាយសម្រាប់ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ រួចទើបធ្វើការបែងចែកទៅតាមសមាមាត្រនៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៤-**

ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ត្រូវបានប្រើប្រាស់សម្រាប់ចំណាយទាំងឡាយដូចដែលមានចែង ក្នុងកថាខ័ណ្ឌទី៣ នៃមាត្រា១៥ នៃអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់ និងត្រូវបានវិភាជន៍ទៅឲ្យឃុំ សង្កាត់នីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម ៖

- ចំណែកស្មើគ្នាជាមូលដ្ឋាន
- ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នីមួយៗ (ដោយផ្អែកតាមឯកសាររបស់ក្រសួងផែនការ )
- សន្ទស្សន៍ភាពក្រីក្រនៃ ឃុំ សង្កាត់នីមួយៗ (ដោយផ្អែកតាមឯកសាររបស់ក្រសួងផែនការ )

សមាមាត្រនៃមូលនិធិអភិវឌ្ឍន៍មូលដ្ឋានចំពោះសន្ទស្សន៍នីមួយៗខាងលើ ត្រូវបានកំណត់ដូចខាងក្រោម៖

| ឆ្នាំថវិកា | ចំណែកស្មើគ្នាជាមូលដ្ឋាន | ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នីមួយៗ | សន្ទស្សន៍ភាពក្រីក្រ ក្នុងឃុំសង្កាត់នីមួយៗ |
|---|---|---|---|
| ឆ្នាំថវិកា២០១១ | ៣៥% | ៣៥% | ៣០% |
| ឆ្នាំថវិកា២០១២ | ៣៥% | ៣៥% | ៣០% |
| ឆ្នាំថវិកា២០១៣ | ៣៥% | ៣៥% | ៣០% |

**មាត្រា ៥-**

